# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

## ជំពូក ៩
## សុវត្ថិភាព និង សុខុមាលភាពវិជ្ជាជីវៈ
## "តម្រូវការទូទៅ"

---

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣ កែង ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១ | ០២៣-៨៨១-៤៩២
គេហទំព័រ: www.cmaa.gov.kh

# មាតិកា

មាតិកា ........................................................................................................................ ២
សេចក្តីផ្តើម ........................................................................................................................ ៣
សុវត្ថិភាព និង សុខុមាលភាពវិជ្ជាជីវៈ- តម្រូវការទូទៅ........................................................................ ៤
១.ទ្រង់ទ្រាយ ........................................................................................................................ ៤
២.ធាតុផ្សំនៃប្រព័ន្ធសុវត្ថិភាព  និង សុខុមាលភាពវិជ្ជាជីវៈ ..................................................................... ៤
២.១. តម្រូវការទូទៅ ............................................................................................................... ៤
២.២. ការទទួលខុសត្រូវរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ..៤
២.៣. ការទទួលខុសត្រូវរបស់និយោជក ......................................................................................... ៥
២.៤. ការទទួលខុសត្រូវរបស់និយោជិក.......................................................................................... ៦
ឧប្បសម្ព័ន្ធ ក ការប្រតិបត្តិប្រព័ន្ធសុវត្ថិភាព  និងសុខុមាលភាពវិជ្ជាជីវៈ ................................................... ៧
ឧប្បសម្ព័ន្ធ ខ ក្រុមអប់រំអំពីមេរោគហ៊ីវ/អេដស៍ ............................................................................ ១០

# សេចក្តីផ្តើម

ថ្វីត្បិតតែមានកាតព្វកិច្ចក្រោមច្បាប់ការងារជាតិ និងអន្តរជាតិព្រមទាំងស្តង់ដាសកម្មភាពកំចាត់មីនជាតិ និងអន្តរជាតិក៏ដោយ ក៏សកម្មភាពកំចាត់មីនតម្រូវឲ្យមានការយកចិត្តទុកដាក់ពីភារកិច្ច និងស្មារតីជាប់ខាតលើបញ្ហាសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈពីសំណាក់អ្នកគ្រប់គ្រងគ្រប់លំដាប់។

ជាការចាំបាច់ណាស់ដែលត្រូវមានការបញ្ជាក់អត្ថន័យនៃពាក្យ "សុវត្ថិភាព" នៅក្នុងន័យនៃសកម្មភាពកំចាត់មីន។ មានន័យថា ស្ថានភាពប្រកបដោយសុវត្ថិភាពមិនមែនបានន័យថាគ្រោះថ្នាក់ត្រូវបានយកចេញទាំងអស់ឡើយ តែបានន័យថា គ្រោះថ្នាក់ត្រូវបានកាត់បន្ថយដល់កំរិតមួយតាមនីតិវិធីសុវត្ថិភាព ដែលរៀបចំឡើងដើម្បីកាត់បន្ថយគ្រោះថ្នាក់ដល់អ្នកដោះមីន ដែលមានលក្ខណៈសមស្រប និងអាចទទួលយកបាន។

អ្នកគ្រប់គ្រងកម្មវិធី និងគំរោងសកម្មភាពកំចាត់មីន ត្រូវសំរេចអោយបាននូវបរិយាកាសសុវត្ថិភាពការងារដោយការរៀបចំការគ្រប់គ្រង និងការត្រួតពិនិត្យអោយមានប្រសិទ្ធភាព បង្កើតការអនុវត្តន៍ជាក់ស្តែង ដែលផ្តល់ជាវិភាគទានក្នុងការកាត់បន្ថយគ្រោះថ្នាក់ ការជ្រើសរើសសំភារៈដែលមានសុវត្ថិភាពពេញលេញ ការផ្តល់ការបណ្តុះបណ្តាលអោយបានសមរម្យ និងត្រូវមានបរិក្ខាការពារខ្លួនដ៏មានប្រសិទ្ធភាព។

ដោយសង្កេតឃើញថា កិច្ចប្រតិបត្តិការសកម្មភាពដោះមីននៅកម្ពុជាមានលក្ខណៈធំធេងនោះ គេមិនអាចផ្តល់នូវសេចក្តីបញ្ជាក់ទាំងស្រុងត្រឹមត្រូវគ្រប់ខ្ទាត់បានគ្រប់ស្ថានការឡើយ។ ដូចនេះ ប្រតិបត្តិករដោះមីនត្រូវបង្កើត និងថែរក្សានីតិវិធី និងកិច្ចដំណើរការ ដែលអាចផ្តល់សុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ តាមរយៈការកំណត់នូវកំរិតគ្រោះថ្នាក់វាយតំលៃ និងកាត់បន្ថយគ្រោះថ្នាក់នោះទៅតាមប្រព័ន្ធមួយដែលសមស្រប និងទាន់ពេលវេលា។

គោលបំណងនៃស្តង់ដានេះ គឺផ្តល់ការណែនាំក្នុងការបង្កើត និងអនុវត្តប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈសំរាប់ប្រើប្រាស់ក្នុងសកម្មភាពកំចាត់មីននៅកម្ពុជា។

# សុវត្ថិភាព និង សុខុមាលភាពវិជ្ជាជីវៈ - តម្រូវការទូទៅ

## ១. ទូទៅ

គោលបំណងនៃស្តង់ដានេះ គឺផ្តល់ការណែនាំក្នុងការបង្កើត និងអនុវត្តប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និង សុខុមាលភាពវិជ្ជាជីវៈ សំរាប់ប្រើប្រាស់ក្នុងសកម្មភាពកំចាត់មីននៅកម្ពុជា ត្រូវអានស្តង់ដានេះ ដោយភ្ជាប់ទៅ នឹង ស្តង់ដាជំពូក១០ ជំពូក១១ ជំពូក ០៤ និង ជំពូក ១០.៤០ និងច្បាប់ការងាររបស់កម្ពុជា។

ក. ស្តង់ដាជំពូក១០ ផ្តល់ការបញ្ជាក់ការណែនាំច្បាស់លាស់សំរាប់សុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈនៅការដ្ឋាន ដោះមីន

ខ. ស្តង់ដាជំពូក១១ ផ្តល់ការបញ្ជាក់ និងការណែនាំច្បាស់លាស់អំពីបរិក្ខារការពារខ្លួន

គ. ស្តង់ដាជំពូក១០.៤០ ផ្តល់ការបញ្ជាក់ និងការណែនាំច្បាស់លាស់ សំរាប់ការផ្គត់ផ្គង់បរិក្ខារពេទ្យដល់កិច្ច ប្រតិបត្តិការបោសសំអាតមីន

ឃ. ស្តង់ដាជំពូក០៤ ផ្តល់ការបញ្ជាក់ និងការណែនាំច្បាស់លាស់សំរាប់ការរៀបចំឃ្លាំង ការដឹកជញ្ជូន និងការប្រើ ប្រាស់គ្រឿងផ្ទុះ

## ២.ធាតុនៃប្រព័ន្ធសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ

### ២-១- តម្រូវការទូទៅ

អាជ្ញាធរមីន រួមជាមួយនិយោជកសកម្មភាពកំចាត់មីនទាំងអស់ គួរបង្កើត និងថែរក្សាប្រព័ន្ធគ្រប់គ្រង សុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈដោយដាក់បញ្ចូលកាតព្វកិច្ចការងារ និងការទទួលខុសត្រូវ ក្រោមច្បាប់របស់ កម្ពុជា ជាពិសេសច្បាប់ការងាររបស់និយោជក និងនិយោជិក។

### ២-២- ការទទួលខុសត្រូវរបស់អាជ្ញាធរមីន

អាជ្ញាធរមីន ត្រូវអនុម័តលើបទដ្ឋាន ក្រមអនុវត្តការងារ និងគោលការណ៍ណែនាំបច្ចេកទេស ដែលពាក់ព័ន្ធ នឹងការអនុវត្តន៍ច្បាប់សុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈរបស់ប្រតិបត្តិករដោះមីនក្នុងអំឡុងពេលផ្តល់ប័ណ្ណទទួល ស្គាល់ព្រមទាំងៈ

ក. ផ្តល់ពត៌មាន និងណែនាំដល់និយោជកទាំងអស់នូវទស្សនៈក្នុងការលុបបំបាត់ ឬកាត់បន្ថយគ្រោះថ្នាក់អោយ បានច្រើនតាមតែអាចធ្វើបាន

ខ. បង្កើនការសិក្សា និងស្រាវជ្រាវដើម្បីកំណត់អោយបាននូវគ្រោះថ្នាក់ដល់សុវត្ថិភាព និងសុខភាពព្រមទាំងរក មធ្យោបាយនានា ដើម្បីជំនះគ្រោះថ្នាក់ទាំងនោះ

គ. ត្រូវធ្វើការពិនិត្យឡើងវិញជារើយៗនូវច្បាប់ជាតិ ដែលពាក់ព័ន្ធនឹងបញ្ហាសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ

ឃ.ធ្វើការពិនិត្យឡើងវិញ នូវបរិយាកាសការងារសកម្មភាពកំចាត់មីនកម្ពុជា ដោយយោងទៅលើបទពិសោធន៍ និង ភាពរីកចំរើននៃបច្ចេកវិជ្ជា

អាជ្ញាធរមីនត្រូវរៀបចំអនុវត្ត និងថែរក្សាប្រព័ន្ធគ្រប់គ្រងច្បាប់សុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈដោយ អនុលោមតាមស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា។

## ២-៣- ការទទួលខុសត្រូវរបស់និយោជក

**និយោជកត្រូវៈ**

ក. ផ្តល់ និងថែរក្សាកន្លែងធ្វើការ គ្រឿងយន្ត និងសំភារៈ ព្រមទាំងអនុវត្តនីតិវិធីនៃការងារ ដែលមានសុវត្ថិភាព ដើម្បីលុបបំបាត់ ឬកាត់បន្ថយកំរិតគ្រោះថ្នាក់អោយបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន

ខ. ផ្តល់នូវការត្រួតពិនិត្យ និងបណ្តុះបណ្តាលអោយបានដិតដល់ (ការអភិវឌ្ឍន៍ និងការបណ្តុះបណ្តាលរំលឹកឡើងវិញសមរម្យ)

គ. ផ្តល់បរិក្ខាការពារខ្លួនគ្រប់គ្រាន់ដល់និយោជិកដោយមិនគិតថ្លៃ

ឃ. ផ្តល់ការថែទាំសុខភាព និងគាំទ្រកិច្ចសង្គ្រោះបន្ទាន់ដល់និយោជិកដោយមិនគិតថ្លៃក្នុងករណីមានគ្រោះថ្នាក់

ង. តែងតាំង ប្រគល់សិទ្ធិ និងបង្កើតគណៈកម្មាធិការ ដើម្បីបង្ហាញកំណត់ហេតុ និងបញ្ចូនទស្សនៈនិយោជិកលើបញ្ហាសុវត្ថិភាព និងសុខភាពវិជ្ជាជីវៈ។ ក្នុងន័យនេះ ត្រូវផ្តល់ដល់អ្នកដែលទទួលសិទ្ធិ និងគណៈកម្មាធិការនូវពត៌មាន និងការណែនាំសមស្រប

ច. ដាក់ចេញនូវច្បាប់សុវត្ថិភាព និងការព្រមានពីបញ្ហាសុវត្ថិភាពជាលាយល័ក្ខអក្សរ ហើយប្រកាសជូនដំណឹងដល់និយោជិកគ្រប់ៗគ្នាអោយបានយល់

ឆ. ផ្ទៀងផ្ទាត់ការប្រតិបត្តិតាមស្តង់ដា និងគោលការណ៍ណែនាំអំពីសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈព្រមទាំងអនុវត្តប្រព័ន្ធសុវត្ថិភាព និងការត្រួតពិនិត្យសុខភាពអោយបានញឹកញាប់

ជ. រៀបចំថែទាំរបាយការណ៍សុវត្ថិភាព រាប់បញ្ចូលទាំងរបាយការណ៍គ្រោះថ្នាក់ និងឧប្បទ្ទវហេតុនៅក្នុងវិជ្ជាជីវៈ

ឈ. ធានាថាមានការធានារ៉ាប់រងយ៉ាងសមរម្យសំរាប់និយោជិកទាំងអស់ ចំពោះមរណភាព ការបាត់បង់សមត្ថភាពពលកម្ម និងរបួសព្រមទាំងការធានារ៉ាប់រងចំពោះភាគីទី៣។ សូមអានស្តង់ដាជំពូក ០២

ប្រតិបត្តិករដោះមីនទាំងអស់(ក្នុងនាមជានិយោជក) ត្រូវរៀបចំអនុវត្ត ថែរក្សាប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ និងធ្វើផែនការអោយស្របទៅនឹងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា។ ការណែនាំស្តីពីការអនុវត្តន៍សុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ មានចែងនៅក្នុងឧប្បសម្ព័ន្ធក ហើយការណែនាំពីក្រុម ពាក់ព័ន្ធនឹងបញ្ហាហ៊ីវ/អេដស៍ មានចែងនៅក្នុងឧប្បសម្ព័ន្ធខ។

## ២-៤- ការទទួលខុសត្រូវរបស់និយោជិក

និយោជិកមានកាតព្វកិច្ចច្បាស់លាស់ចំពោះបញ្ហាសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ។ និយោជិកទាំងអស់ត្រូវៈ

ក. យកចិត្តទុកដាក់ថែរក្សាសុវត្ថិភាពផ្ទាល់ខ្លួន និងបុគ្គលិកដទៃទៀត ដែលអាចរងគ្រោះដោយសារអំពើរបស់ពួកគេ ឬដោយការភ្លេចផ្លាំងនៅកន្លែងធ្វើការ

ខ. អនុវត្តតាមសេចក្តីណែនាំដែលបានចែងសំរាប់ការប្រព្រឹត្ត និងសុវត្ថិភាពរបស់ខ្លួន

គ. ប្រើប្រាស់ឧបករណ៍សុវត្ថិភាព បរិក្ខារការពារខ្លួនអោយបានជាប់លាប់ត្រឹមត្រូវ និងថែទាំឧបករណ៍ទាំងនេះអោយបានល្អ

ឃ. រាយការណ៍ជូនថ្នាក់ដឹកនាំជាបន្ទាន់ ចំពោះស្ថានការណ៍ទាំងឡាយដែលខ្លួនជឿជាក់ថានឹងអាចមានគ្រោះថ្នាក់ដោយមានហេតុផលច្បាស់លាស់ ហើយខ្លួនមិនអាចកែតម្រូវបាន។

## ឧបសម្ព័ន្ធ ក
## (ជាធម្មតា)
## ការអនុវត្តន៍ច្បាប់សុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ
## ធាតុផ្សំនៃប្រព័ន្ធសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ

### ១.១. តម្រូវការទូទៅ

ប្រតិបត្តិករដោះមីនគួរបង្កើត និងថែរក្សាប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ។ ប្រព័ន្ធគ្រប់គ្រងនេះ គួរដាក់បញ្ចូលនូវធាតុផ្សំសំខាន់ៗដូចខាងក្រោមៈ

### ១.២. ច្បាប់សុវត្ថិភាព និង សុខុមាលភាពវិជ្ជាជីវៈ

ត្រូវរៀបចំអោយមានបទដ្ឋានប្រតិបត្តិការនៃសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈរបស់ប្រតិបត្តិករដោះមីនទុកជាឯកសារច្បាស់លាស់ និងជូនដំណឹងជាលាយល័ក្ខអក្សរ និងដោយផ្ទាល់មាត់ដល់និយោជិកទាំងអស់អោយបានដឹងដោយសរសេរជាភាសាអង់គ្លេស និងភាសាខ្មែរ។

### ១.៣. ការធ្វើគំរោងផែនការ

ការរៀបចំផែនការត្រូវដាក់បញ្ចូលទាំងការបង្កើត ការថែរក្សាឯកសារច្បាប់ និងបទដ្ឋានប្រតិបត្តិការដូចខាងក្រោម:

ក. ធ្វើផែនការលើការកំណត់អត្តសញ្ញាណ ការសិក្សាវាយតំលៃ និងការគ្រប់គ្រងកំរិតគ្រោះថ្នាក់អោយបានច្បាស់ (ក្នុងបទដ្ឋានប្រតិបត្តិការ ត្រូវដាក់បញ្ចូលនូវនីតិវិធី និងការណែនាំរបៀបធ្វើការងារសំរាប់សកម្មភាពដោះមីនទាំងអស់នៅក្នុងកន្លែងធ្វើការ រាប់ញ្ចូលទាំងសកម្មភាពរបស់អ្នកចុះកិច្ចសន្យាបន្ត និងភ្ញៀវដែលទៅទស្សនៈកិច្ចកន្លែងធ្វើការនោះផងដែរ។ ការធ្វើផែនការនេះ ត្រូវមាននីតិវិធីសំរាប់គ្រប់គ្រងជំងឺ និងបង្ការជំងឺផងដែរ)។

ខ. តម្រូវការផ្លូវច្បាប់ និងតម្រូវការផ្សេងៗទៀត (ប្រតិបត្តិករដោះមីនត្រូវអនុវត្តតាមច្បាប់ការងាររបស់កម្ពុជា និងស្តង់ដានៃផ្នែកផ្សេងទៀត ដែលមានការអនុវត្តន៍ដ៏ប្រសើរ)។

គ. ប្រតិបត្តិករដោះមីន គួរគិតគូរពីគោលដៅនៃការបង្កើតឲ្យមានប្រព័ន្ធសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ ព្រមទាំងកាត់បន្ថយឧប្បទ្ទវហេតុ និងគ្រោះថ្នាក់។ ប្រតិបត្តិករដោះមីនត្រូវបង្កើត និងថែរក្សានូវវិន័យ ដែលជាផ្នែកដ៏សំខាន់នៃបញ្ហាសុវត្ថិភាពនៅការដ្ឋានដោយការបង្កើត និងថែរក្សាបទដ្ឋានប្រតិបត្តិការ ដែលផ្តល់ឱកាសដល់និយោជិកក្នុងការកំណត់នូវបញ្ហា និងបង្កើននូវសុវត្ថិភាពនៅកន្លែងធ្វើការ។

ឃ. កម្មវិធីគ្រប់គ្រងសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ

### ១.៤. ការអនុវត្តន៍ និង កិច្ចប្រតិបត្តិការ

ការអនុវត្តន៍ និងកិច្ចប្រតិបត្តិការ ត្រូវរាប់បញ្ចូលទាំងការបង្កើត ការថែរក្សាឯកសារផែនការ និងឯកសារនីតិវិធីសំរាប់:

ក. រចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ រាប់បញ្ចូលទាំងការកំណត់អត្តសញ្ញាណ និងការទទួលខុសត្រូវនៃមន្ត្រីផ្នែកសុវត្ថិភាពរបស់ប្រតិបត្តិករ។ ប្រតិបត្តិករដោះមីនអន្តរជាតិ ត្រូវដាក់បញ្ចូល ពីផែនការផ្ទេរការទទួលខុសត្រូវនេះដល់បុគ្គលិកក្នុងស្រុក។

ខ. ការបណ្តុះបណ្តាល និងការអប់រំយល់ដឹង ត្រូវដាក់បញ្ចូលទាំងការបណ្តុះបណ្តាល និងការកំណត់ពេលបណ្តុះបណ្តាលឡើងវិញពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ និងការទទួលខុសត្រូវរបស់និយោជិកទាំងអស់ក្នុងការថែទរក្សាសុវត្ថិភាព និងសុខភាពផ្ទាល់ខ្លួនរបស់ពួកគេ ជួយទប់ស្កាត់កុំអោយមានគ្រោះថ្នាក់ព្រមទាំងការជួយដល់ការសង្គ្រោះបឋម។ គួរបញ្ចូលផងដែរនូវការកំណត់អត្តសញ្ញាណ និងការធ្វើបាយការណ៍នានានៃឱកាសសំរាប់បង្កើនសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ។ ការបើកវគ្គបណ្តុះបណ្តាលជាផ្លូវការ គួរផ្តល់ដល់បុគ្គលិកដែលមានការតែងតាំងអោយទទួលខុសត្រូវក្នុងការគ្រប់គ្រងសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ ដូចជាប្រធានក្រុម និងមន្ត្រីសុវត្ថិភាពជាដើម ។

គ. ការប្រឹក្សា និងការទំនាក់ទំនង

ឃ. ការរៀបចំឯកសារបទដ្ឋានប្រតិបត្តិការ គួរដាក់បញ្ចូលនូវឯកសារនីតិវិធី និងសេចក្តីណែនាំការងារសំរាប់អនុវត្តប្រព័ន្ធសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ។ បទដ្ឋាននេះ ត្រូវដាក់បញ្ចូលផងដែរនូវនីតិវិធី ធ្វើរបាយការណ៍សវនកម្ម

ង. គ្រប់គ្រងឯកសារទិន្នន័យសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ

ច. ប្រតិបត្តិការត្រួតពិនិត្យ

ឆ. ការរៀបចំផែនការឆ្លើយតប និងការសង្គ្រោះបន្ទាន់ (ប្រតិបត្តិករដោះមីន ត្រូវរៀបចំអោយមានផែនការឆ្លើយតបកិច្ចសង្គ្រោះបន្ទាន់សំរាប់ការដ្ឋានដោះមីន ព្រមទាំងរៀបចំឲ្យមានការសាកល្បងជារើយៗ។ ផែនការនេះ គួរដាក់បញ្ចូលសេចក្តីបញ្ជាក់ពីសមត្ថភាព លទ្ធភាពនៃការព្យាបាល និងមធ្យោបាយជំលៀសជនរងគ្រោះ ដូចដែលបានកំណត់នៅក្នុងផែនការ)

## ១.៥. ការពិនិត្យឡើងវិញ និង សកម្មភាពកែតម្រូវ

ការពិនិត្យមើលឡើងវិញ និងសកម្មភាពកែតម្រូវ គួររាប់បញ្ចូលទាំងការបង្កើត និងការថែរក្សាផែនការ និងនីតិវិធីសំរាប់៖

ក. វិធានការអនុវត្តច្បាប់សុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ និងការត្រួតពិនិត្យ

ខ. គ្រោះថ្នាក់ឧប្បទ្ទវហេតុ និងភាពមិនស្របគ្នា (ប្រតិបត្តិករដោះមីន ត្រូវបង្កើតការថែរក្សាឯកសារបទដ្ឋានប្រតិបត្តិការ ដែលកំណត់អត្តសញ្ញាណ និងបែងចែកដាច់ពីគ្នារវាងឧប្បទ្ទវហេតុគ្រោះថ្នាក់ដោយសារការដោះមីន និងឧប្បទ្ទវហេតុគ្រោះថ្នាក់ដោយសារមីន។ ស្តង់ដាសំរាប់រៀបចំឯកសារ ធ្វើរបាយការណ៍ឧប្បទ្ទវហេតុ និងគ្រោះថ្នាក់ដោយសារដោះមីន មានចែងនៅក្នុងស្តង់ដាជំពូក០៥)

គ. ការកែតម្រូវ និងវិធានការការពាររាប់បញ្ចូលទាំងការត្រួតពិនិត្យជំងឺ

ឃ. កំណត់ត្រានានា និងកំណត់ត្រាពីការគ្រប់គ្រង

ង. សវនកម្ម ឬការត្រួតពិនិត្យ

## ឧបសម្ព័ន្ធ ខ
## (ជាពត៌មាន)
## ក្រមអប់រំអំពីហ៊ីវ/អេដស៍

ពត៌មានខាងក្រោម គឺផ្អែកលើឯកសាររបស់អង្គការពលកម្មអន្តរជាតិ "ច្បាប់របស់អង្គការពលកម្មអន្តរជាតិ អប់រំអំពីហ៊ីវ/អេដស៍ និងច្បាប់ការងារនៅទូទាំងពិភពលោក"។

### អារម្ភកថា

ហ៊ីវ/អេដស៍ គឺជាជំងឺរាតត្បាត ដែលសព្វថ្ងៃក្លាយជាវិបត្តិសកល ហើយជាជំងឺ ដែលគួរអោយភ័យខ្លាចបំផុតចំពោះការអភិវឌ្ឍន៍ និងវឌ្ឍនភាពសង្គម។ ក្រៅពីការឈឺចាប់ខ្លោចផ្សារដែលធ្លាក់ទៅលើបុគ្គល និងគ្រួសាររបស់ពួកគេ ជំងឺរាតត្បាតនេះប៉ះពាល់យ៉ាងខ្លាំងដល់សង្គម និងការរៀបចំសេដ្ឋកិច្ចសង្គម។ ជំងឺហ៊ីវ/អេដស៍ គឺជាការគំរាមគំហែងដ៏ធំចំពោះការងារនៅទូទាំងពិភពលោក។ វាធ្វើអោយប៉ះពាល់ដល់កំលាំងពលកម្ម កាត់បន្ថយនូវប្រាក់ចំណូល និងកំពុងធ្វើអោយតំលៃនៃផលិតផលគ្រប់វិស័យទាំងអស់ឡើងថ្លៃយ៉ាងខ្ពស់ តាមរយៈការធ្លាក់ចុះនៃផលិតផលដោយបង្កើនតំលៃពលកម្ម ការបាត់បង់ជំនាញ និងបទពិសោធន៍។ លើសពីនេះ ហ៊ីវ/អេដស៍ កំពុងធ្វើអោយប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានក្នុងការបំពេញការងារ ពិសេសចំពោះការរើសអើង ការប្រកាន់ចំពោះកម្មករអ្នកដែលកំពុងរស់នៅជាមួយ និងផលប៉ះពាល់ដោយសារជំងឺហ៊ីវ/អេដស៍។

### គោលដៅ

គោលដៅនៃក្រមនេះ គឺដើម្បីផ្តល់គោលការណ៍ណែនាំពីបញ្ហាហ៊ីវ/អេដស៍នៅកន្លែងធ្វើការ។ គោលការណ៍នេះ បានចែងពីចំណុចសំខាន់ៗនៃសកម្មភាពដូចខាងក្រោមៈ

ក. ការពារការឆ្លងរាលដាលនៃជំងឺហ៊ីវ/អេដស៍

ខ. ការគ្រប់គ្រង និងការសម្រាលផលប៉ះពាល់នៃជំងឺហ៊ីវ/អេដស៍នៅកន្លែងធ្វើការ

គ. ការផ្គត់ផ្គង់ និងការថែទាំសុខភាពកម្មករដែលរងការប៉ះពាល់ និងឆ្លងមេរោគហ៊ីវ/អេដស៍

ឃ.លុបបំបាត់នូវការរើសអើងទោះជាដឹងការពិត ឬដឹងថាអ្នកនោះមានមេរោគហ៊ីវក៏ដោយ

### វិទ្ធាន / ទ្រង់ទ្រាយ

ក្រមនេះអនុវត្តចំពោះ ៖

ក. និយោជក និងកម្មករទាំងអស់(រាប់បញ្ចូលទាំងអ្នកដាក់ពាក្យសុំការងារធ្វើ)ក្នុងវិស័យកំចាត់មីន

ខ. គ្រប់ទិដ្ឋភាពនៃការងារតាមផ្លូវការ និងក្រៅផ្លូវការ

### គោលការណ៍សំខាន់ៗ

**១. ការទទួលស្គាល់ថា មេរោគហ៊ីវ/អេដស៍ ជាបញ្ហាសំរាប់កន្លែងធ្វើការ**

មេរោគហ៊ីវ/អេដស៍ ជាបញ្ហាធំនៅកន្លែងធ្វើការ ដែលត្រូវចាត់ទុកដូចជំងឺធ្ងន់ធ្ងរដទៃទៀតនៅក្នុងកន្លែងធ្វើការ។ វាមិនត្រឹមតែធ្វើអោយប៉ះពាល់ដល់កំលាំងពលកម្មប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់ដល់កន្លែងធ្វើការ ដែលជាផ្នែកនៃសហគមន៍ក្នុងមូលដ្ឋាន ត្រូវមានតួនាទីប្រយុទ្ធប្រឆាំងយ៉ាងស្រួចស្រាវ ដើម្បីទប់ស្កាត់ការរាតត្បាត និងការរាលដាលមេរោគនេះ។

## ២. ការមិនរើសអើង

ក្នុងស្មារតីយោគយល់គ្នានៅក្នុងការងារ ការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរនៃអ្នកដែលរងការប៉ះពាល់ ឬឆ្លងមេរោគហ៊ីវ/អេដស៍ នោះមិនត្រូវរើសអើងចំពោះកម្មករ ទោះជាដឹងការពិតថាអ្នកនោះមានមេរោគហ៊ីវឡើយ។ ការបែងចែកឲ្យដាច់លើមនុស្ស ដែលរស់នៅជាមួយអ្នក ដែលមានមេរោគហ៊ីវ/អេដស៍ គឺជាការបង្កើនការទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគហ៊ីវ/អេដស៍។

## ៣. សិទ្ធិស្មើភាពគ្នានៃភេទ

ទំហំនៃការឆ្លងមេរោគហ៊ីវ/អេដស៍ ត្រូវបានគេទទួលស្គាល់។ យោងតាមហេតុផលជីវសាស្រ្ត វប្បធម៌សង្គម និងសេដ្ឋកិច្ច ស្រ្តីងាយនឹងឆ្លងមេរោគហ៊ីវ/អេដស៍ជាងបុរស។ ការរើសអើង ប្រកាន់ភេទ ការបន្ទាបបន្ថោកឋានៈស្រ្តីក្នុងសង្គម និងកត្តាអវិជ្ជមានជាច្រើនទៀត នាំអោយស្រ្តីងាយរងការប៉ះពាល់ដោយមេរោគហ៊ីវ។ ដូច្នេះការទំនាក់ទំនងដោយមិនប្រកាន់ភេទ និងការផ្តល់សិទ្ធិស្មើគ្នាដល់ស្រ្តីជាកត្តាសំខាន់ ដើម្បីការពារការឆ្លងរាតត្បាតនៃមេរោគហ៊ីវ និងជាកត្តាដែលនាំអោយស្រ្តីទប់ស្កាត់ ការឆ្លងមេរោគហ៊ីវ/អេដស៍បានដោយជោគជ័យ។

## ៤. បរិយាកាសការងារប្រកបដោយសុខមាលភាព

បរិយាកាសកន្លែងការងារ គួរជាកន្លែងដែលមានសុវត្ថិភាព និងសុខុមាលភាពសំរាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីការពារការឆ្លងមេរោគហ៊ីវដោយអនុលោមតាមបញ្ញត្តិទាំងឡាយនៃអនុសញ្ញាឆ្នាំ១៩៨១ លេខ១៥៥ ស្តីពីសុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ។ បរិយាកាសការងារប្រកបដោយសុខុមាលភាព ជាមធ្យោបាយធ្វើអោយរាងកាយគំនិតប្រាជ្ញាវាងវៃនៅក្នុងការងារ ហើយការទទួលយកការងារសមស្របតាមសមត្ថភាព អាស្រ័យដោយរាងកាយ និងគំនិតប្រាជ្ញារបស់ពួកគេ។

## ៥. ការប្រាស្រ័យទាក់ទងនៅក្នុងសង្គម

ជោគជ័យនៃការអនុវត្តន៍គោលការណ៍ច្បាប់ និងកម្មវិធីនៃជំងឺហ៊ីវ/អេដស៍ ទាមទារនូវកិច្ចសហការ និងការទុកចិត្តរវាងនិយោជិក កម្មករ និងអ្នកតំណាងរបស់ពួកគេ ហើយពេលខ្លះជាមួយនឹងរដ្ឋាភិបាលផង ដោយការទាក់ទងយ៉ាងសកម្មជាមួយកម្មករដែលរងការប៉ះពាល់ និងឆ្លងមេរោគហ៊ីវ/អេដស៍។

## ៦. ការធ្វើតេស្តរកមេរោគសំរាប់គោលបំណងនៃការបណ្តេញចេញពីការងារ ឬពីដំណើរការការងារ

ការពិនិត្យឈាមដើម្បីរកមេរោគហ៊ីវ/អេដស៍ មិនគួរអនុវត្តចំពោះអ្នកដាក់ពាក្យសុំការងារ ឬបុគ្គលិក ដែលកំពុងបំរើការងារនោះឡើយ។

## ៧. ភាពអាថ៌កំបាំង

មិនត្រូវសួរនាំអ្នកដាក់ពាក្យសុំការងារ ឬកម្មករអោយប្រាប់ពត៌មានផ្ទាល់ខ្លួនអំពីការឆ្លងមេរោគហ៊ីវឡើយ។ សហសេវិក ក៏មិនត្រូវបង្ហាញពត៌មានផ្ទាល់ខ្លួនបែបនេះទៅដៃគូរខ្លួនដែរ។ ចំពោះទិន្នន័យពត៌មានផ្ទាល់ខ្លួនរបស់កម្មករ ដែលមានផ្ទុកមេរោគហ៊ីវ ត្រូវបានការពារដោយច្បាប់រក្សាភាពអាថ៌កំបាំង ស្របទៅនឹងច្បាប់អនុវត្តការងាររបស់អង្គការពលកម្មអន្តរជាតិ ស្តីពីការការពារទិន្នន័យពត៌មានផ្ទាល់ខ្លួនរបស់កម្មករ ឆ្នាំ១៩៩៧។

## ៨.ការបន្តទំនាក់ទំនងការងារ

ការឆ្លងមេរោគហ៊ីវមិនមែនជាបុព្វហេតុសំរាប់បញ្ចប់ការងារឡើយ។ ដូចអ្នកជំងឺផ្សេងទៀតដែរ អ្នកមានជំងឺហ៊ីវ អាចធ្វើការងារសមស្របទៅនឹងជំងឺខ្លួនបានយូរតាមដែលអាចធ្វើបាននៅពេល ដែលគេទទួលបាននូវការព្យាបាលសមរម្យ។

## ៩. ការការពារ

ការឆ្លងមេរោគហ៊ីវ អាចការពារបាន។ មធ្យោបាយនានា ដើម្បីការពារការឆ្លងមេរោគ អាចធ្វើទៅបានតាមរយៈយុទ្ធសាស្ត្រផ្សេងៗ ដែលមានគោលដៅត្រឹមត្រូវទៅតាមលក្ខខ័ណ្ឌ និងវប្បធម៌ដ៏មានឥទ្ធិពល។ មានវិធីការពារជាច្រើនទៀត តាមរយៈការផ្លាស់ប្តូរឥរិយាបថ ចំណេះដឹង ការព្យាបាល និងការបង្កើតឡើងនូវបរិយាកាសមិនរើសអើង។ ដៃគូរបស់សង្គម គឺជាជំហាមួយក្នុងការបង្កើនកិច្ចខិតខំប្រឹងប្រែងការពារ ជាពិសេសចំពោះការផ្លាស់ប្តូរអាកប្បកិរិយា ឥរិយាបថ តាមរយៈការផ្តល់ពត៌មាន ការអប់រំ និងការបង្ហាញលើកត្តាសេដ្ឋកិច្ចសង្គមនានា។

## ១០. ការពិនិត្យព្យាបាល និងការគាំទ្រ

សាមគ្គីភាព ការយកចិត្តទុកដាក់ និងការគាំទ្រ ជាជំរើសមួយក្នុងការត្រួសត្រាយដើម្បីឆ្លើយតបទៅនឹងហ៊ីវ/អេដស៍ក្នុងប្រព័ន្ធការងារពិភពលោក។ កម្មករទាំងអស់រាប់បញ្ចូលទាំងកម្មករ ដែលមានផ្ទុកមេរោគហ៊ីវមានសិទ្ធិទទួលសេវាសុខភាពគ្រប់គ្រាន់ មិនត្រូវរើសអើងចំពោះពួកគេ ក្រុមគ្រួសាររបស់ពួកគេ ក្នុងការទទួលបានផលប្រយោជន៍ពីការងារ និងលក្ខន្តិកៈនៃកម្មវិធីសន្តិសុខសង្គមឡើយ។